## សន្ធិដ្ឋិភាព (conspiracy)

សន្និដ្ឋិភាព ជាកិច្ចព្រមព្រៀងរវាងមនុស្សពីរ ឬច្រើនអ្នក ដើម្បីប្រព្រឹត្តទង្វើខុសច្បាប់ណាមួយ។ សន្ធិដ្ឋិភាព ត្រូវបានចាត់ថាជាបទល្មើស (substantive offense)។ ក៏ប៉ុន្តែ ជាទូទៅ វាត្រូវបានចាត់ថាជាទម្រង់នៃការទទួលខុសត្រូវក្នុងទម្រង់សមគំនិត (complicity)។

ប្រទេសកំមុនឡ (common law) ដូចជាសហរដ្ឋអាមេរិក ដើម្បីដាក់ឲ្យបុគ្គលទទួលខុសត្រូវ វាទាមទារឲ្យបុគ្គលប្រព្រឹត្តនូវអំពើច្បាស់ក្រឡែតណាមួយ (overt cat)។ ផ្ទុយទៅវិញ សម្រាប់ប្រទេសស៊ីវិលឡ (civil law) គ្រាន់តែមានកិច្ចព្រមព្រៀងសន្ធិដ្ឋិភាព គឺគ្រប់គ្រាន់ហើយ សម្រាប់ការទទួលខុសត្រូវ។

អ្នកចូលរួមនឹងទទួលខុសត្រូវព្រហ្មទណ្ឌក្នុងអំឡុងពេលរៀបចំផែនការប្រព្រឹត្តបទល្មើសជាមួយដៃគូរ។

មានប្រភេទនៃការទទួលខុសត្រូវចំនួនបី៖ ១.អ្នកចូលរួម នឹងទទួលខុសត្រូវចំពោះទង្វើរបស់ដៃគូរ ដែលប្រព្រឹត្តល្មើសហួសពីអ្វី ដែលបានឯកភាព ក្នុងករណី ដែលគាត់អាចព្យាករណ៍ថាទង្វើនោះ អាចនឹងកើតមានឡើង។ ២. អ្នកចូលរួមគ្រប់រូប ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចគ្នា (សហរដ្ឋអាមេរិក) ដោយគ្មានការបែងចែក រវាងចារី និងជនសមគំនិត (អាឡឺម៉ង់)។ ជាចុងក្រោយ ការទទួលខុសត្រូវតាមទម្រង់នេះពង្រីកដល់អ្នកបរិច្ចាគ (contributor) ទោះបីមិនមានផែនការព្រហ្មទណ្ឌរួម ឧទាហរណ៍ មិនមានកិច្ចព្រមព្រៀងសន្ធិដ្ឋិភាព រវាងជនជាប់ចោទ និងក្រុមមនុស្សក្តី។

ការទាមទារនូវកិច្ចព្រមព្រៀងនេះ បង្ហាញពីភាពខុសគ្នារវាងទម្រង់នៃការទទួលខុសត្រូវសន្ធិដ្ឋិភាព និង ការជួយ (aiding) ដែលជនសមគំនិត បានផ្តល់ជំនួយដល់ការប្រព្រឹត្តបទល្មើស។ ការជួយនេះ ទាមទារនូវផលវិបាកធន់ល្មម (substantial effect) ដល់សកម្មភាពរបស់ចារីនៃបទល្មើស (perpetrator) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 279-280)។